# កិច្ចព្រមព្រៀង ស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័ន រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង បណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើររឿងក្តីជួញដូរមនុស្ស

**ដោយយោងតាម** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ដែលមាត្រា ៤៦ បានចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។"

**ដោយយោងតាម** ព្រះរាជក្រម ជ.ស/រកម/០២ ៩៦/០១ ចុះថ្ងៃទី ២៩កុម្ភៈ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។

**ដោយយោងតាម** ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី ការប្រឆាំងឧក្រិដ្ឋឆ្លងដែន នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០០៥ និងបានផ្តល់សច្ចាប័នលើពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និង ផ្តន្ទាទោសលើអំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦។

**ដោយយោងតាម** អនុស្សរណៈនៃការយោគយល់គ្នារ វាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ធ្វើនៅសៀមរាប, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣។

**ដោយយោងតាម** អនុស្សរណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៃមហាអនុតំបន់មេគង្គ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា នៅទីក្រុងយ៉ាងហ្គូន នៃសហភាពមីយ៉ាន់ម៉ា កាលពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៤។

**ដោយយោងតាម** កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ ធ្វើនៅទីក្រុងហាណូយ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥។

**ដោយយល់ឃើញថា** ព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានបែបបទ និងវិធីសាស្ត្រ ពិសេសនៅក្នុងរឿងក្តីជួញដូរមនុស្ស និងច្បាប់ស្តីពីភស្តុតាង ។

**ដោយយល់ឃើញថា** ភាគីទាំងអស់ ទទួលស្គាល់ថា មានតែកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះទេ ទើបដំណើរការរឿងក្តីជួញដូរមនុស្ស និង ការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះទទួលបានជោគជ័យ ។

**យើង** ដែលជាអ្នកចុះហត្ថលេខាខាងក្រោម បានយល់ព្រម លើកិច្ចព្រមព្រៀងស្តីពី គោលការណ៍ណែនាំអនុវត្តន៍ និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើររឿងក្តីជួញដូរមនុស្ស ដើម្បីកំណត់ និយមន័យ(ជំពូក១), ការជួយសង្គ្រោះ(ជំពូក២), ការកំណត់ជនរងគ្រោះ (ជំពូក៣), កិច្ចការពារជនរងគ្រោះ(ជំពូក៤), អនីតិជន(ជំពូក៥), បញ្ហាវេជ្ជសាស្ត្រ(ជំពូក៦), ទីប្រឹក្សាច្បាប់(ជំពូក៧), ភស្តុតាង និងចំលើយសាក្សី(ជំពូក៨), សេវា លក្ខខណ្ឌ និងបុគ្គលិកមណ្ឌល(ជំពូក៩), សមត្ថកិច្ចមណ្ឌល (ជំពូក១០), ទីភ្នាក់ងារទំនាក់ទំនងដំបូង (ជំពូក១១), សមាហរណកម្ម(ជំពូក១២), និង កិច្ចសហប្រតិបត្តិការរវាងភាគីទាំងអស់ (ជំពូក១៣) ។

## ជំពូក១_និយមន័យ

**ប្រការ១._**

- អំពើជួញដូរមនុស្ស នៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់ដោយច្បាប់។ យោងតាមច្បាប់ចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្ម លើមនុស្សបានកំណត់និយមន័យតាម មាត្រា ៣ ថា:

"ជនណាអូសទាញមនុស្ស ទោះបីស្រី ឬប្រុស អនីតិជន ឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីល្បួងលោម សន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសមិខ្លួនសុខចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែង ឬប្រើថ្នាំសន្លប់ស្មារតី និងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ ។"

- ក្នុងករណីបទល្មើសជួញដូរមនុស្សឆ្លងដែន និយមន័យអំពើជួញដូរមនុស្ស បានកំណត់នៅក្នុងពិធីសារបន្ថែម ស្តីពីការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសលើអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារនៃអនុសញ្ញាអង្គការសហ ប្រជាជាតិប្រឆាំងក្រុមឧក្រិដ្ឋកម្មឆ្លងដែន។

(ក) "ការជួញដូរមនុស្ស" មានន័យថា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬ ការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកំលាំង ឬការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជា ការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភលើអំណាច ឬតួនាទី ទៅលើជនដែលងាយរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកំរៃផ្សេងៗ ដើម្បីអោយមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀតក្នុងគោលបំណងដើម្បីធ្វើការកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ច ត្រូវរាប់បញ្ចូលជាអប្បបរិមានូវការធ្វើការកេងប្រវ័ញ្ចពេស្យាចារលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទាសភាព ភាពជាអ្នកបំរើដាច់ថ្លៃ ឬ ការដកយកសរីរាង្គជាដើម។

(ខ) ការយល់ព្រមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំពោះអាជីវកម្ម ដែលបានធ្វើឡើងដោយចេតនាដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) នៃប្រការនេះ។ នឹងមិនអាចយកជាការបានឡើយ ប្រសិនបើមធ្យោបាយណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌ (ក) ត្រូវបានយកមកប្រើប្រាស់។

(គ) ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារ ក្នុងគោលបំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា "ការជួញដូរមនុស្ស" ទោះបីជាអំពើនេះមិនជាប់ពាក់ពន្ធ័ទៅនឹងមធ្យោបាយណាមួយ ដែលមានចែងក្នុងវាក្យខ័ណ្ឌ (ក) នៃប្រការនេះក៏ដោយ។

(ឃ) "កុមារ" មានន័យថា ជនណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ។

- ការជួញដូរមនុស្ស មានគោលបំណងកេងប្រវ័ញ្ចតាមរូបភាពយ៉ាងតិចបំផុតដូចតទៅ ដោយយោងតាមនៃអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ (មាត្រា៣) និង នៃកិច្ចព្រមព្រៀងរវាងកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ (មាត្រា២) :

១-ពេស្យាចារ

២-ការងារក្នុងគេហដ្ឋាន ដូចជា ការងារផ្ទះដែលគេបង្ខំ ឬ កេងប្រវ័ញ្ច

៣-ពលកម្មកុមារ

៤-ការងាររំលោះបំពុល

៥-អាពាហ៍ពិពាហ៍ ក្នុងឆន្ទៈទុច្ចរិត

៦-សុំកូនក្លែងក្លាយ ក្នុងឆន្ទៈទុច្ចរិត

៧-ការកំសាន្ត និងទេសចរណ៍ផ្លូវភេទ

៨-រូបភាព និង សម្ភារៈអាសអាភាស

៩-ការសុំទាន និងពលកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ គ្រោះថ្នាក់ និងកេងប្រវ័ញ្ច

១០-ការប្រើប្រាស់ក្នុងសកម្មភាពទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌ

១១-ការប្រើប្រាស់គ្រឿងញៀនជាមធ្យោបាយដើម្បីធ្វើអោយស្ត្រី និងកុមារក្លាយជាទាសករ។

**ប្រការ ២.-**

ទីភ្នាក់ងារ នៅក្នុងកិច្ចព្រមព្រៀងនេះ គឺទីភ្នាក់ងារគាំទ្រជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស មានៈ ស្ថាប័នរដ្ឋ និង អង្គការសង្គមស៊ីវិលជាតិ/អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

**ប្រការ ៣.-**

ទីភ្នាក់ងារទំនាក់ទំនងដំបូង គឺជាស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិលជាតិ/អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលមិនមានមណ្ឌលសំរាប់ជនរងគ្រោះដោយការជួញដូរទេ តែជាទីភ្នាក់ងារដែលបានទទួលជនរងគ្រោះដំបូង និងជាបណ្ដោះអាសន្ន ហើយបញ្ជូនបន្តទៅកាន់មណ្ឌលថែទាំ។

## ជំពូក២-ការជួយសង្គ្រោះ

**ប្រការ ៤.-**

សុវត្ថិភាព សិទ្ធិ និងសុខុមាលភាពរបស់ជនរងគ្រោះ គឺជាការព្រួយបារម្ភចំបង។ គោលការណ៍ណែនាំក្នុងការជួយសង្គ្រោះជនរងគ្រោះមាន :

- ក្រោយពេលប្រតិបត្តិការ នគរបាលមានសិទ្ធិរក្សាទុកជនដែលបានរំដោះ ដើម្បីធ្វើការសំភាសន៍ និងធ្វើកំណត់ហេតុ។ ក្នុងករណីអាចធ្វើទៅបាន គប្បីជ្រើសរើសនគរបាលជាស្ត្រី ឱ្យសំភាសន៍ជាមួយជនរងគ្រោះជាស្ត្រី ឬកុមារ។ ការសំភាសន៍ ត្រូវធ្វើជាបន្ទាន់ ក្រោយពេលប្រតិបត្តិការរំដោះ។ ក្នុងករណីការសំភាសន៍លើសពីពីរថ្ងៃ នគរបាល ត្រូវសុំយោបល់ពីព្រះរាជអាជ្ញា។
- បន្ទាប់ពីការសំភាសន៍ នគរបាលត្រូវកំណត់ជាបណ្ដោះអាសន្ន នូវអត្តសញ្ញាណជនរងគ្រោះ និងជនមិនរងគ្រោះ ព្រមទាំងអាយុជនរងគ្រោះ។
- ក្រោយពីកំណត់អត្តសញ្ញាណហើយ នគរបាលត្រូវផ្ដល់ព័ត៌មានដល់ជនរងគ្រោះ អំពីសេវា និងសិទ្ធិតាមផ្លូវច្បាប់ តាមរយៈភាសាដែលជនរងគ្រោះស្ដាប់បាន។ សេវាខាងលើនេះត្រូវផ្ដល់ឱ្យ ជនរងគ្រោះ ទោះបីជាជនរងគ្រោះ យល់ព្រម ឬមិនយល់ព្រម សហការជាមួយនគរបាលក៏ដោយ។

- បន្ទាប់មក នគរបាលត្រូវបញ្ជូនជនរងគ្រោះ ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត/ក្រុង។

## ជំពូក៣_ការកំណត់ជនរងគ្រោះ

**ប្រការ ៥._**

ជាគោលការណ៍ ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឆ្លងដែន ត្រូវកំណត់ដោយប្រើប្រាស់និយមន័យដែលមានចែងនៅក្នុង ពិធីសារស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស។ ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឆ្លងដែន មិនត្រូវចាត់ទុកថាជាជនល្មើសនៅក្នុងច្បាប់អន្តោប្រវេសន្តឡើយ។

**ប្រការ ៦._**

ការសម្រេចលើការកំណត់ជាផ្លូវការ និងចុងក្រោយថា តើបុគ្គលណាមួយជាជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស គឺជាភារកិច្ចរបស់ព្រះរាជអាជ្ញា ឬចៅក្រម។ នគរបាល ឬទីភ្នាក់ងារដែលរកឃើញជនរងគ្រោះ មុនគេ គឺជាអ្នកដែលមានភារកិច្ចកំណត់លើកដំបូង អំពីថាតើជននោះ ជាជនរងគ្រោះដោយសារ អំពើជួញដូរ មនុស្សមែន ឬមិនមែន។ ក្នុងករណីដែលទីភ្នាក់ងារបានកំណត់មុនថា ជនដែលពាក់ព័ន្ធនោះ ជាជនរងគ្រោះ ហើយបន្ទាប់មកទីភ្នាក់ងារនេះ បានបញ្ជូនពត៌មានពីការកំណត់នេះទៅឱ្យនគរបាល តែក្រោយមក ប្រសិនបើនគរបាល ឬព្រះរាជអាជ្ញា ឬចៅក្រម ធ្វើការកំណត់ផ្ទុយពីការកំណត់របស់ទីភ្នាក់ងារនោះ នគរបាល ឬព្រះរាជអាជ្ញា ឬចៅក្រម ត្រូវបញ្ជូនពត៌មាន ពីការកំណត់របស់ខ្លួនទៅឱ្យទីភ្នាក់ងារ ដើម្បីឱ្យទីភ្នាក់ងារនេះ ធ្វើការបញ្ជូនពត៌មាន ឬស្វែងរកពត៌មានបន្ថែមរបស់ខ្លួនទៀត។

## ជំពូក៤_កិច្ចការពារជនរងគ្រោះ

**ប្រការ ៧._**

កិច្ចការពារដល់ជនរងគ្រោះ គឺជាការព្រួយបារម្ភចំបងរបស់ភាគីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ។

**ប្រការ ៨._**

នៅគ្រប់ដំណាក់កាលនៃនីតិវិធីដោះស្រាយរឿងក្តីជួញដូរមនុស្ស អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវហាមឃាត់:

- ថតយករូបភាព ឬសំលេង ឬផ្សព្វផ្សាយពត៌មាន ដែលធ្វើឱ្យសាធារណៈជន ដឹងអំពីអត្តសញ្ញាណ ឯកសារ របស់ជនរងគ្រោះ ឬសាក្សី។
- ផ្សព្វផ្សាយទិន្នន័យ និងសាវតាជាតិ ប្រវត្តិរូប របស់ជនរងគ្រោះ និងសាក្សី។

ចំនុចទាំងពីរខាងលើ អាចលើកលែងបាន លុះត្រាមានការយល់ព្រមពីជនរងគ្រោះ ឬឪពុកម្តាយ ឬអាណាព្យាបាល ក្នុងករណីជនរងគ្រោះជាអនីតិជន ឬជនទៅក្រោមអាណាព្យាបាល ឬក្នុងករណីផ្តល់ផលប្រយោជន៍ល្អបំផុតសំរាប់ជនរងគ្រោះ ។

## ប្រការ ៩.-

នគរបាលត្រូវធ្វើការប៉ាន់ប្រមាណអំពីភាពគ្រោះថ្នាក់ ដែលអាចនឹងកើតមានឡើង និងផ្តល់កិច្ចការពារសុវត្ថិភាព និងសន្តិសុខ ដល់ជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសាក្សី ព្រមទាំងទីភ្នាក់ងារ និងបុគ្គលិកគាំទ្រដល់ជនរងគ្រោះ ។

## ប្រការ ១០.-

ក្នុងករណី ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឆ្លងដែន យល់ព្រមទៅធ្វើជាសាក្សី រហូតដល់ចប់ដំណើរការនៃរឿងក្តីរបស់ជនសង្ស័យ ព្រះរាជអាជ្ញាត្រូវផ្តល់ព័តមានដល់នគរបាលអន្តោប្រវេសន្ត ដើម្បីផ្តល់ការអនុញ្ញាតស្នាក់នៅជាបណ្តោះអាសន្នដល់ជនរងគ្រោះ ។

## ប្រការ ១១.-

រាល់ការស៊ើបអង្កេត ត្រូវធ្វើយ៉ាងណាមិនឱ្យមានការប៉ះពាល់ ដល់សន្តិសុខរបស់ជនរងគ្រោះឡើយ ។ ម្យ៉ាងជាមិនត្រូវឱ្យជនសង្ស័យ ដឹងពីការស៊ើបអង្កេត ដែលពាក់ព័ន្ធដល់ជនរងគ្រោះជាដើម ។

# ជំពូក៥_អំពីអនីតិជន

## ប្រការ ១២.-

គ្រប់រឿងក្តីទាំងអស់ អត្ថប្រយោជន៍របស់អនីតិជន គឺត្រូវគិតគូជាចំបង ។ ឆន្ទះរបស់ជនរងគ្រោះដែលជាអនីតិជននឹងត្រូវគោរព ដរាបណាភាពពេញវ័យរបស់គេក្នុងការសំរេចចិត្ត អាចធ្វើទៅបាន ។

## ប្រការ ១៣.-

ជាគោលការណ៍ នគរបាល ព្រះរាជអាជ្ញា ចៅក្រម ទទួលស្គាល់សំបុត្រកំណើត ឬប័ណ្ណគ្រួសារ ជាភស្តុតាងដ៏សំខាន់ក្នុងការកំណត់អាយុរបស់ជនរងគ្រោះ ។ នៅក្នុងករណីមិនមានឯកសារខាងលើទេ ការកំណត់អាយុជនរងគ្រោះ ត្រូវធ្វើឡើងដោយ គណៈកម្មការសល្យកោសល្យវិច័យជាតិ ឬ គណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង តាមរយៈការពិនិត្យធ្មេញ ឬឆ្អឹងរបស់ជនរងគ្រោះជាដើម ។

អាយុរបស់ជនរងគ្រោះ គឺត្រូវកំណត់យកអាយុ នៅពេលដែលបទល្មើស បានកើតឡើងដំបូង ។

**ប្រការ ១៤.-**

នៅក្នុងករណី ជនណាមួយត្រូវចោទប្រកាន់ពីបទជួញដូរកូនរបស់ខ្លួន ឬជននៅក្រោមអាណាព្យាបាលរបស់ខ្លួន តុលាការអាចដកសិទ្ធិអំណាចមេបា ឬអាណាព្យាបាលបាន ទៅតាមនីតិវិធីច្បាប់។ ក្នុងករណីនេះ ដើម្បីផ្តល់ផលប្រយោជន៍ដល់កុមារ ទីភ្នាក់ងារដែលមានជំនាញចិត្តសាស្ត្រកុមារ អាចចូលរួមផ្តល់ យោបល់បាន។

## ជំពូក៦.-ទេដ្ឋសាស្ត្រ

**ប្រការ ១៥.-**

ក្នុងករណីចាំបាច់ដើម្បីជៀសវាងការបាត់បង់ភស្តុតាង ទីភ្នាក់ងារគាំទ្រជនរងគ្រោះ អាចជួយជនរងគ្រោះតាមរយៈ នគរបាលយុត្តិធម៌ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីជនរងគ្រោះ ក្នុងការស្នើសុំវិញ្ញាបនប័ត្រកោសល្យវិច័យ ទៅគណៈកម្មការសព្យកោសល្យវិច័យថ្នាក់ជាតិ ឬគណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង។

**ប្រការ ១៦.-**

ក្នុងករណីចាំបាច់ ចំពោះរឿងក្តីពាក់ព័ន្ធការរំលោភផ្លូវភេទ ជនរងគ្រោះ ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធ អាចស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច រក្សាទុកវត្ថុដែលអាចជាភស្តុតាង និងភស្តុតាង សំរាប់ដំណើរការដោះស្រាយរឿងក្តីនាពេលខាងមុខ។

**ប្រការ ១៧.-**

ការធ្វើកោសល្យវិច្ច័យ ត្រូវគោរពឆន្ទះរបស់ជនរងគ្រោះ ។

## ជំពូក៧.-ការប្រឹក្សាច្បាប់

**ប្រការ ១៨.-**

នគរបាល ព្រះរាជអាជ្ញា និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ ត្រូវផ្តល់ពត៌មានដល់ជនរងគ្រោះ អំពីពត៌មានខាងផ្នែកច្បាប់ និងនីតិវិធីនៃការធ្វើពាក្យបណ្តឹងប្រឆាំងនឹងជនល្មើស។ ការផ្តល់ពត៌មានដល់ជនរងគ្រោះខាងលើ នេះ ត្រូវធ្វើឡើងជាភាសាដែលជនរងគ្រោះអាចប្រើ និងស្តាប់យល់បាន ។

**ប្រការ ១៩.-**

នគរបាល និងទីភ្នាក់ងារ ត្រូវផ្តល់ការទំនាក់ទំនងសេវាខាងផ្នែកច្បាប់ ដល់ជនរងគ្រោះ។

## ជំពូក៤_ភស្តុតាង និងចំលើយសាក្សី

**ប្រការ ២០.-**

រាល់ចំលើយរបស់ជនរងគ្រោះ ត្រូវរក្សាទុកជាការសំងាត់ ។

**ប្រការ ២១.-**

នៅពេលបើកសវនាការជំនុំជំរះរឿងក្តី ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តុលាការអាចធ្វើជាសំងាត់ ដោយគោរពទៅតាមផលប្រយោជន៍ សេចក្តីថ្លៃថ្នូរ និងភាពឯកជនរបស់ជនរងគ្រោះនោះ ឬអនុញ្ញាតិឱ្យជនរងគ្រោះ ផ្តល់ចំលើយនៅទីកន្លែងដោយឡែក តាមរយៈបណ្តាញកាមីរ៉ាទូរស្សន៍ផ្ទាល់ (តុលាការ អាចស្នើសុំឧបករណ៍បែបនេះ ពីក្រសួងយុត្តិធម៌) ឬអនុញ្ញាតិឱ្យជនរងគ្រោះ ផ្តល់ចំលើយតាមរយៈកាសែតវីដេអូថត។ បើមានការចាំបាច់ តុលាការអាចអនុញ្ញាតិឱ្យអ្នកគាំទ្រ នៅជាមួយជនរងគ្រោះបាន។

**ប្រការ ២២.-**

នៅក្នុងដំណើរការដោះស្រាយរឿងក្តីដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន អាជ្ញាធរមានសមត្ថកិច្ច និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ ត្រូវទទួលខុសត្រូវរកអ្នកបកប្រែភាសា អោយជនរងគ្រោះ នូវភាសាដែលជនរងគ្រោះអាចយល់ និង ស្តាប់បាន។

**ប្រការ ២៣.-**

នៅក្នុងករណី ដែលមានការវាយតំលៃពីគ្រូពេទ្យឯកទេសវិកលវិទ្យា ឬអ្នកឯកទេសផ្នែកចិត្តសាស្ត្រ ថាជនរងគ្រោះមានការប៉ះទង្គិចខាងផ្នែកផ្លូវចិត្ត អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតិឱ្យមានវត្តមានទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ របស់ទីភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ នៅក្នុងដំណើរការសួរយកពិតមានពីជនរងគ្រោះ។

**ប្រការ ២៤.-**

ក្នុងករណីជនរងគ្រោះ មិនអាចរង់ចាំ រហូតដល់ពេលសវនាការបញ្ចប់ ជនរងគ្រោះ អាចផ្តល់សក្ខីកម្មតាមមធ្យោបាយសមស្របណាមួយ ស្របតាមគោលការណ៍ច្បាប់។ វិធីសាស្ត្រក្នុងការផ្តល់ភស្តុតាងតាមជំរើសផ្សេងៗ គួរផ្តល់ឱកាសឱ្យជនរងគ្រោះ ឧទាហរណ៍តាមរយៈការថតវីដេអូ សំភាសន៍នៅទីកន្លែងដោយឡែក បង្ហាញ សក្ខីកម្មមុនពេលសវនាការ ហើយបន្ទាប់មក កំណត់ហេតុនោះ ត្រូវអានក្នុងសវនាការ។

**ប្រការ ២៥.-**

តុលាការ ត្រូវយកចិត្តទុកដាក់ធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ ក្នុងករណីដែលតុលាការយល់ថា អាចមានការគំរាមកំហែងដល់ជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ ឬមធ្យោបាយផ្សេងទៀតដែលធ្វើឱ្យជនរងគ្រោះកែប្រែចំលើយរបស់ខ្លួន។

**ប្រការ ២៦.-**

រាល់កិច្ចសន្យាដែលធ្វើឡើងដោយមានគោលដៅបំរើឱ្យអំពើជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ ឬកិច្ចសន្យាធ្វើឡើងដោយភ្ជាប់ទៅនឹងអំពើជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវទុកជាមោឃៈ។

**ប្រការ ២៧.-**

ភាគីជនរងគ្រោះ អាចសុំមើល សំណុំរឿងរបស់ខ្លួន នៅការិយាល័យក្រឡាបញ្ជីបាន។

## ជំពូក៩.សេវា សក្ខខណ្ឌ និងបុគ្គលិករបស់មណ្ឌល

**ប្រការ ២៨.-**

គោលបំណងរបស់មណ្ឌលគឺ ផ្តល់សុវត្ថិភាព ស្តារនីតិសម្បទានិង ធ្វើសមាហរណកម្ម ដល់ជនរងគ្រោះ។ ដើម្បីសំរេចគោលបំណងនេះ មណ្ឌលត្រូវយកចិត្តទុកដាក់ដល់ការស្តារនីតិសម្បទា (បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការថែទាំសុខភាព សេវាពិគ្រោះយោបល់ ការអប់រំ) និងធ្វើសមាហរណកម្មជនរងគ្រោះទាំងនោះ ទៅរួមរស់ក្នុងគ្រួសារ ឬសហគមន៍វិញ។

ការផ្តល់សេវាខាងលើនេះ មិនត្រូវអោយមានឥទ្ធិពលជាអវិជ្ជមាន ឬធ្វើអោយជនរងគ្រោះ មានការឈឺចាប់ ផ្លូវកាយនិងផ្លូវចិត្តឡើងវិញឡើយ។

**ប្រការ ២៩.-**

នៅពេលជនរងគ្រោះម្នាក់ចូលមកដល់ មណ្ឌលត្រូវធ្វើការវិភាគពីសេចក្តីត្រូវការ និងសមត្ថភាពរបស់ជនរងគ្រោះ ដើម្បីកំណត់ថាតើការថែរក្សាប្រភេទណាដែលគួរផ្តល់អោយជនរងគ្រោះ។

**ប្រការ ៣០.-**

មណ្ឌលត្រូវសម្របសម្រួលដល់ជនរងគ្រោះជាជនជាតិខ្មែរ អោយចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណ-បណ្ណ នៅក្នុងសហគមន៍របស់គេ ដើម្បីទទួលបានឱកាសការងារ និងផលប្រយោជន៍ ស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៣១.-**

គ្រប់មណ្ឌលទាំងអស់ ត្រូវផ្តល់សេវាថែទាំសុខភាពដល់ជនរងគ្រោះ ដោយអាចប្រើប្រាស់សេវាសុខាភិបាលរបស់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិត។ ក្នុងករណីចាំបាច់ដែលតំរូវអោយមានជាប្រចាំនូវសេវាសុខាភិបាលក្នុងមណ្ឌល មណ្ឌលត្រូវគោរពតាមច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

**ប្រការ ៣២.-**

បុគ្គលិកមណ្ឌល ត្រូវរាយការណ៍រាល់សភាពជំងឺទៅប្រធានមណ្ឌលជាបន្ទាន់។ ចំពោះជនរងគ្រោះដែលមានជំងឺឆ្លង ត្រូវបំបែកចេញពីជនរងគ្រោះដទៃទៀត និងត្រូវព្យាបាលដោយយកចិត្តទុកដាក់។ បើមានជំងឺធ្ងន់ធ្ងរ ប្រធានមណ្ឌល ត្រូវរាយការណ៍ ឬបញ្ជូនទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ។

**ប្រការ ៣៣.-**

មណ្ឌលត្រូវផ្តល់ការអប់រំអោយជនរងគ្រោះគ្រប់ៗគ្នា ទៅតាមអាយុ កំរិតនៃការអប់រំដែលធ្លាប់បានទទួល និងកំរិតនៃការយល់ដឹង។ រាល់សេចក្តីត្រូវការពិសេសរបស់ជនរងគ្រោះ ត្រូវយកចិត្តទុកដាក់។ ការអប់រំគួររួមមានទាំងអក្សរសាស្ត្រ នព្វន្តសាស្ត្រ និងបំណិនជីវិត ផងដែរ។

មណ្ឌលត្រូវផ្តល់ឱកាសដល់ជនរងគ្រោះ បានផ្សារភ្ជាប់ទៅនឹងសង្គម ពតិមានជាតិ និងអន្តរជាតិ តាមរយៈទូរទស្សន៍ វិទ្យុ ការសែត ការចូលរួមនៅក្នុងសកម្មភាពសហគមន៍ និងសិក្សារៀនសូត្រក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

**ប្រការ ៣៤.-**

មណ្ឌលអាចផ្តល់ឱកាសអោយជនរងគ្រោះ ធ្វើការងារអោយមណ្ឌល តែមិនត្រូវបង្ខំ ឬគំរាមកំហែងឱ្យជនរងគ្រោះធ្វើការងារនោះទេ។ ការងារដែលជនរងគ្រោះធ្វើ ត្រូវតែជាការងារស្រាលៗ និងមិនមានផលប៉ះពាល់ដល់ការសិក្សា ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលបំណិនជីវិត ឬសេវាផ្សេងទៀតដែលពាក់ព័ន្ធដល់ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មរបស់ពួកគេឡើយ។

ជនរងគ្រោះម្នាក់ៗ មិនត្រូវធ្វើការងារលើសពី ៨ម៉ោងក្នុង ១សប្តាហ៍ទេ។ រយៈពេលនេះ ត្រូវបែងចែកអោយពេញមួយសប្តាហ៍ ពោលគឺកំណត់ ច្រើនបំផុតត្រឹម ២ម៉ោងក្នុង ១ថ្ងៃ ។

ជនរងគ្រោះត្រូវទទួលបានប្រាក់កំរៃពីការងារ ដែលពួកគេបានបំពេញនៅក្នុងមណ្ឌល។ ប្រាក់កំរៃនេះជនរងគ្រោះអាចធ្វើការចំណាយផ្ទាល់ខ្លួន។ ចំណែកដែលនៅសល់ ត្រូវថែរក្សាដោយមណ្ឌល ហើយមណ្ឌលត្រូវប្រគល់អោយជនរងគ្រោះវិញ នៅពេលគេចាកចេញពីមណ្ឌល។

**ប្រការ ៣៥.-**

មណ្ឌលត្រូវរៀបចំអោយមានសកម្មភាពកំសាន្តប្រកបដោយការច្នៃប្រឌិត សំរាប់ជនរងគ្រោះ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។ ជនរងគ្រោះមួយចំនួនមានភាពភ័យខ្លាច ក្នុងការរៀបរាប់រឿងរ៉ាវអតីតកាលរបស់ខ្លួន ហើយជនរងគ្រោះនោះ មានបំណងរៀបរាប់រឿងរ៉ាវរបស់ខ្លួន តាមរយៈការសំដែងសិល្បៈ របាំ ឬបទភ្លេង។ មធ្យោបាយពិគ្រោះយោបល់ជនរងគ្រោះតាមបែបច្នៃប្រឌិតនេះ គឺមានអត្ថប្រយោជន៍យ៉ាងខ្លាំង ចំពោះជនរងគ្រោះ។

**ប្រការ ៣៦.-**

មណ្ឌលត្រូវបែងចែកការស្នាក់នៅរបស់ជនរងគ្រោះ ទៅតាមភេទ លើកលែងតែក្នុងករណីបងប្អូនបង្កើតដែលមានអាយុក្រោម ១៣ ឆ្នាំ។

**ប្រការ ៣៧.-**

មណ្ឌលត្រូវផ្តល់ ឬបញ្ជូនជនរងគ្រោះ ទៅរកជំនួយផ្នែកច្បាប់ទៅតាមការចាំបាច់។ ក្នុងករណី ជនរងគ្រោះពុំមានឪពុក-ម្តាយ ឬអាណាព្យាបាលទេនោះ មណ្ឌលអាចពឹងពាក់មេធាវីឱ្យជួយការពារជនរងគ្រោះបាន។

មណ្ឌលត្រូវលើកទឹកចិត្ត អោយជនរងគ្រោះ ផ្តល់ចំលើយនៅចំពោះមុខតុលាការ ឬដាក់ពាក្យបណ្តឹងទាមទារ សំណងជំងឺចិត្តពីជនល្មើស។

**ប្រការ ៣៨.-**

ក្នុងដំណើរការដោះស្រាយរឿងក្តី ដែលទាក់ទងនឹងជនរងគ្រោះកំពុងស្នាក់នៅក្នុងមណ្ឌល ប្រធានមណ្ឌលត្រូវមានកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។ ទន្ទឹមនឹងនេះ ប្រធានមណ្ឌល ត្រូវជួយលើកទឹកចិត្តដល់ជនរងគ្រោះ ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដោយគ្មានការបង្ខិតបង្ខំ។

**ប្រការ ៣៩.-**

មណ្ឌលត្រូវលើកទឹកចិត្ត ក្នុងការផ្ទេរជនរងគ្រោះទៅឱ្យស្ថាប័នដទៃទៀត ដើម្បីផ្តល់សេវាផ្សេងៗទៀតដល់ជនរងគ្រោះ ដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការថែរក្សាសុខភាពពិសេសណាមួយ ប្រសិនបើសេវានោះមានគុណភាពល្អ ដល់ជនរងគ្រោះ។ មណ្ឌល មិនសន្មតថាអាចផ្តល់សេវាទាំងអស់ ដោយផ្ទាល់ ដល់ជនរងគ្រោះនោះឡើយ។ ប៉ុន្តែបុគ្គលិកសង្គមដែលទទួលបន្ទុកលើជនរងគ្រោះនិមួយៗ ត្រូវដើរតួនាទី ជាអ្នកគ្រប់គ្រងករណីជនរងគ្រោះ ដោយធ្វើការតាមដានពីសេវាដែលផ្តល់ឱ្យពីអ្នកដទៃ ហើយត្រូវធានាថា សេវានោះអាចជួយដល់ជនរងគ្រោះ ។

### ប្រការ ៤០.-

មណ្ឌលនីមួយៗត្រូវមានគោលនយោបាយ បទបញ្ជាផ្ទៃក្នុង និងកម្មវិធីច្បាស់លាស់ សំរាប់ជនរងគ្រោះស្នាក់នៅ។ ជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលថែទាំ ត្រូវទទួលបានការណែនាំអំពីសិទ្ធិ និងពេលវេលាស្នាក់នៅក្នុងមណ្ឌលតាំងពី ពេលចូលមកដំបូង។

### ប្រការ ៤១.-

បទវិន័យផ្សេងៗរបស់មណ្ឌល ត្រូវតែចែងអោយបានច្បាស់លាស់ ឬបើមិនដូច្នោះទេ ត្រូវពន្យល់ណែនាំដោយពាក្យសំរាយដែលអាចអោយជនរងគ្រោះងាយយល់។

### ប្រការ ៤២.-

បទវិន័យរបស់មណ្ឌល ត្រូវរៀបចំឡើងក្នុងបរិបទមួយសមស្រប ពោលគឺមិនមានឥទ្ធិពលជាអវិជ្ជមានដល់សុខមាលភាព ផ្លូវកាយ និងស្មារតីរបស់ជនរងគ្រោះទេ។

បទវិន័យរបស់មណ្ឌល មិនត្រូវចែងពីការវាយដំ បង្ខាំងទុក ធ្វើទារុណកម្ម ឬគ្រប់គ្រងដោយអមនុស្សធម៌ចំពោះជនរងគ្រោះទេ ទោះបីជនរងគ្រោះមានកំហុសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

### ប្រការ ៤៣.-

មណ្ឌលត្រូវប្រឹងប្រែងអោយអស់ពីសមត្ថភាព ក្នុងការថែរក្សាភាពស្ងប់ស្ងាត់ និងសណ្តាប់ធ្នាប់ក្នុងមណ្ឌល ដើម្បីការពារមណ្ឌល ពីការកុំអោយក្លាយជាគោលដៅងាយស្រួលមួយ របស់ក្រុមជួញដូរមនុស្ស ធ្វើការសងសឹក ឬដណ្តើមយកជនរងគ្រោះណាម្នាក់ទៅវិញ និងដើម្បីការពារជនរងគ្រោះដែលជាសាក្សី។

### ប្រការ ៤៤.-

បើមានសភាពការប្រែប្រួលពាក់ព័ន្ធនឹងសន្តិសុខរបស់ជនរងគ្រោះ ប្រធានមណ្ឌលត្រូវរាយការណ៍ជាបន្ទាន់ដល់នគរបាលមានសមត្ថកិច្ចដែលនៅជិតបំផុត។

### ប្រការ ៤៥.-

មណ្ឌលត្រូវមានបរិយាកាសល្អបរិសុទ្ធ ពន្លឺគ្រប់គ្រាន់ ម្ហូប ទ្វារនិងបង្អួចធំៗ។ មណ្ឌលគួរមានទីធ្លាសំរាប់អោយជនរងគ្រោះលេងកំសាន្តប្រកបដោយសុវត្ថិភាព។

ជនរងគ្រោះត្រូវមានឱកាសធ្វើលំហាត់ប្រាណ និងចូលរួមនៅក្នុងសកម្មភាពកំសាន្ត យ៉ាងហោចណាស់មួយម៉ោងក្នុងមួយថ្ងៃ នៅតាមទីធ្លារបស់មណ្ឌល។

**ប្រការ ៤៦.-**

មណ្ឌលត្រូវមានអនាម័យល្អគ្រប់គ្រាន់ និងត្រូវណែនាំជនរងគ្រោះអំពីអនាម័យផ្ទាល់ខ្លួន ដើម្បីថែរក្សាភាពស្អាត និងសុខមាលភាព ។ មណ្ឌលត្រូវផ្តល់ សំលៀកបំពាក់ ដល់ជនរងគ្រោះអោយបានសមរម្យ ។

មណ្ឌលត្រូវមាន ទូ ឬប្រអប់មានសោរ សំរាប់ជនរងគ្រោះ ទុកដាក់របស់របរផ្ទាល់ខ្លួនបាន។

**ប្រការ ៤៧.-**

មណ្ឌលត្រូវផ្តល់អាហារដែលមានសារជាតិ និងទឹកស្អាតគ្រប់គ្រាន់ ស្របទៅតាមពេលវេលាអាហារទៀងទាត់ ។

**ប្រការ ៤៨.-**

មណ្ឌលត្រូវបង្កលក្ខណៈ និងលើកទឹកចិត្ត អោយមានទំនាក់ទំនង រវាងជនរងគ្រោះ និងជនរងគ្រោះ ជាពិសេស ចំពោះជនរងគ្រោះដែលមានវិបត្តិប្រហាក់ប្រហែលគ្នា តែមណ្ឌល ត្រូវចាត់វិធានការទប់ស្កាត់ រាល់កំហុសឆ្គង នៃទំនាក់ទំនងផ្លូវភេទរវាង ជនរងគ្រោះ និងជនរងគ្រោះ ។

មណ្ឌលត្រូវចាត់វិធានការទប់ស្កាត់ រាល់កំហុសឆ្គង នៃទំនាក់ទំនងផ្លូវភេទ រវាងបុគ្គលិកមណ្ឌល និងជនរងគ្រោះ។

**ប្រការ ៤៩.-**

មណ្ឌលត្រូវអនុញ្ញាតអោយជនរងគ្រោះ ទាក់ទងជាមួយសមាជិកគ្រួសារ មិត្តភ័ក្រ តាមការមកសួរសុខ ទុក្ខ ឬសំបុត្រ ឬទូរស័ព្ទ ក្នុងករណីចាំបាច់ ។

សិទ្ធិក្នុងការទាក់ទងជាមួយសមាជិកគ្រួសារ មិត្តភ័ក្រ ត្រូវហាមឃាត់ ក្នុងករណីមណ្ឌលមានហេតុផលសមស្របបញ្ជាក់ថា សមាជិកគ្រួសារ ឬ មិត្តភ័ក្រនោះ មានការពាក់ព័ន្ធនឹងការជួញដូរជនរងគ្រោះ។

**ប្រការ ៥០.-**

មណ្ឌលត្រូវគោរព សេរីភាពជំនឿរបស់ជនរងគ្រោះអោយបានពេញលេញ និងមិនត្រូវបង្ខំអោយជនរងគ្រោះចូលរួមនៅក្នុងសកម្មភាពសាសនាផ្សេងៗឡើយ ។

**ប្រការ ៥១.-**

នៅក្នុងមណ្ឌល មិនត្រូវមានភាពលំអៀងចំពោះជនរងគ្រោះ ដោយផ្អែកលើៈ អាយុ ភេទ រូបកាយ ពិការភាព ញាតិភាព ជាតិសាសន៍ ឬ សាសនា នោះទេ ។

**ប្រការ ៥២.-**

ជនរងគ្រោះត្រូវអនុញ្ញាតអោយចូលរួមរាល់សកម្មភាពរបស់មណ្ឌល ។ មណ្ឌលត្រូវធ្វើការត្រិះរិះពិចារណា រាល់គំនិតយោបល់ ឬការព្រួយបារម្ភផ្សេងៗរបស់ជនរងគ្រោះ ទាក់ទងទៅនឹងដំណើរការប្រព្រឹត្តិទៅរបស់មណ្ឌល។ គំនិត យោបល់របស់ជនរងគ្រោះ អាចបង្ហាញឡើងជាចំហ និងដោយសេរី ។

**ប្រការ ៥៣.-**

មណ្ឌល ត្រូវយកចិត្តទុកដាក់រាល់ការតវ៉ារបស់ជនរងគ្រោះណាម្នាក់ ហើយត្រូវចាត់វិធានការផ្សេងៗ ដើម្បីដោះស្រាយលើការតវ៉ានោះ។ មណ្ឌលគួរពិចារណាបង្កើតយន្តការមួយ ដើម្បីអង្កេតលើបណ្តឹងស្តីពី ការបំពានលើសិទ្ធិជនរងគ្រោះ។

**ប្រការ ៥៤.-**

បុគ្គលិកមណ្ឌលរបស់ទីភ្នាក់ងារគាំទ្រជនរងគ្រោះ យ៉ាងហោចណាស់ត្រូវមានៈ ប្រធានមណ្ឌល អ្នកប្រឹក្សាយោបល់ អ្នកថែទាំ បុគ្គលិកសង្គម និងសន្តិសុខ។

រាល់បុគ្គលិកមណ្ឌលទាំងអស់ ត្រូវទទួលការបណ្តុះបណ្តាលស្តីពី មូលដ្ឋានត្រឹមត្រូវមួយ ដោយផ្អែកទៅលើ តួនាទីការងារដាក់លាក់របស់បុគ្គលនីមួយៗ នៅក្នុងវិស័យការងារជាក់ស្តែងរបស់ពួកគេ ។

**ប្រការ ៥៥.-**

អ្នកថែទាំ ត្រូវយល់ពីតំលៃ និងសេចក្តីត្រូវការរបស់ជនរងគ្រោះ។ ភារកិច្ចចំបងរបស់អ្នកថែទាំគឺ ជួយជនរងគ្រោះដើម្បីអោយទទួលបានការអភិវឌ្ឍន៍យ៉ាងពេលលេញទាំងផ្នែករាងកាយ ប្រាជ្ញាស្មារតី និង បំណិនជីវិត ដើម្បីធ្វើអោយពួកគេអាចរស់នៅដោយខ្លួនឯងបាន។

**ប្រការ ៥៦.-**

អ្នកផ្តល់ប្រឹក្សា ត្រូវជួយស្តារសុខភាពផ្លូវចិត្តដល់ជនរងគ្រោះ។ អ្នកផ្តល់ប្រឹក្សា ត្រូវមានជំនាញ ផ្នែកពិគ្រោះយោបល់ តាមរយៈការបណ្តុះបណ្តាលសមស្របមួយ មុននឹងធ្វើការជាមួយជនរងគ្រោះ។

មណ្ឌលគួរមានអ្នកផ្តល់ប្រឹក្សា ដែលអាចផ្លាស់ប្តូរគ្នាបាន ក្នុងរយៈពេល ២៤ ម៉ោង សំរាប់សេវា ពិគ្រោះយោបល់ ដល់ជនរងគ្រោះ។

**ប្រការ ៥៧.-**

បុគ្គលិកសង្គមកិច្ច ដើរតួយ៉ាងសំខាន់ ក្នុងដំណើរការគ្រប់គ្រងករណី ការធ្វើសមាហរណកម្ម និង ការតាមដានវាយតំលៃជនរងគ្រោះ ដែលត្រូវបានបញ្ជូន ឬត្រូវបានធ្វើសមាហរណកម្មទៅកាន់សហគមន៍វិញ ។ បុគ្គលិកសង្គមកិច្ចត្រូវរាយការណ៍ទៅប្រធានមណ្ឌលជាបន្ទាន់ អំពីបញ្ហាចាំបាច់ ទាក់ទងនឹងជនរងគ្រោះណាម្នាក់។

**ប្រការ ៥៨.-**

បុគ្គលិកសង្គមសុខ មានភារកិច្ចថែរក្សាសុវត្ថិភាពរបស់ជនរងគ្រោះ នៅក្នុងមណ្ឌល ដូចជា ត្រូវតែប្រយ័ត្នប្រយែងរាល់ប្រការផ្សេងៗដែលកើតឡើងនៅក្នុងបរិវេណ និងជុំវិញមណ្ឌល។ ក្នុងករណីចាំបាច់ បុគ្គលិកសន្តិសុខត្រូវរាយការណ៍ទៅប្រធានមណ្ឌលដើម្បីចាត់ការបន្ត។

**ប្រការ ៥៩.-**

មណ្ឌលមិនត្រឹមតែជ្រើសរើសបុគ្គលិក ដែលមានសមត្ថភាពឯកទេស ដូចជាអ្នកចិត្តសាស្ត្រសង្គម គ្រូពេទ្យ អ្នកឯកទេសខាងទីផ្សារការងារ អ្នកស្ម័គ្រចិត្តប៉ុណ្ណោះទេ មណ្ឌលអាចជ្រើសរើសអតីតជនរងគ្រោះអោយធ្វើជាអ្នកប្រឹក្សាយោបល់ ( មិត្តអប់រំមិត្ត ) ។

**ប្រការ ៦០.-**

លក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងជំពូក៩ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តទៅតាម ប្រកាសស្តីពីបទដ្ឋានអប្បបរមាសំរាប់មណ្ឌលថែទាំកុមារ ដែលនឹងចេញដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូក១០.-សមត្ថកិច្ចរបស់មណ្ឌល

**ប្រការ ៦១.-**

ទីភ្នាក់ងារគាំទ្រជនរងគ្រោះទាំងអស់ ត្រូវមានការអនុញ្ញាត និងទទួលស្គាល់ជាផ្លូវការ ឱ្យបំពេញភារកិច្ចរបស់ខ្លួន។ ទីភ្នាក់ងារអន្តរជាតិ ត្រូវចុះបញ្ជីជាដំបូងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំណែកឯទីភ្នាក់ងារក្នុងស្រុក ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ។ បន្ទាប់មក ទីភ្នាក់ងារទាំងឡាយនោះ ត្រូវចុះកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងចុះកិច្ចព្រមព្រៀងជាមួយក្រសួងដទៃទៀតដែលពាក់ព័ន្ធ។

**ប្រការ ៦២.-**

មណ្ឌលដែលបានចុះបញ្ជីត្រឹមត្រូវតាមប្រការ៦១ ទទួលបានសិទ្ធិគ្រប់គ្រងលើជនរងគ្រោះ នៅក្រោមការថែរក្សារបស់ខ្លួន។ សិទ្ធិគ្រប់គ្រងរបស់មណ្ឌល គឺជាការសំរេចចិត្ត ពាក់ព័ន្ធទៅនឹងជនរងគ្រោះ ដោយផ្អែកលើគោលការណ៍ផលប្រយោជន៍ជាចំបង និងពិចារណាទៅលើទស្សនៈ និងគំនិតរបស់ជនរងគ្រោះ។

នៅពេលមណ្ឌលទទួលបានជនរងគ្រោះដោយអនុវត្តន៍ត្រឹមត្រូវតាម ប្រការ៦៣ នោះមណ្ឌល នឹងមិនត្រូវបានចោទប្រកាន់ពីការបង្ខាំងជនរងគ្រោះខុសច្បាប់ទេ។

**ប្រការ ៦៣.-**

រាល់ការស្នាក់នៅក្នុងមណ្ឌល ត្រូវមានការយល់ព្រមជាមុន ពីជនរងគ្រោះ ឬឪពុក-ម្ដាយ ឬអាណាព្យាបាលរបស់ជនរងគ្រោះ និងមណ្ឌលផងដែរ ។

ក្នុងករណីមណ្ឌលយល់ឃើញថា ការដែលជនរងគ្រោះមិនយល់ព្រមស្នាក់នៅក្នុងមណ្ឌល អាចនឹងបង្កគ្រោះថ្នាក់ សារជាថ្មីម្ដងទៀតដល់ជនរងគ្រោះ ដូចនេះមណ្ឌលត្រូវរាយការណ៍ ទៅអាជ្ញាធរមានសមត្ថកិច្ច ជាបន្ទាន់ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចនោះ ចាត់វិធានជាបណ្ដោះអាសន្ន ឱ្យទាន់ពេលវេលា ។

ក្នុងការទទួលជនរងគ្រោះ មណ្ឌលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជាមួយនឹងអ្នកប្រគល់ជនរងគ្រោះ។ ទំរង់បែបបទទទួលជនរងគ្រោះ ត្រូវចុះហត្ថលេខាដោយប្រធានមណ្ឌល ជនរងគ្រោះ ឬបុគ្គលតំណាងអោយជនរងគ្រោះ (ឪពុកម្ដាយ ឬអាណាព្យាបាល ឬបុគ្គលណាម្នាក់ដែលមានការទទួលខុសត្រូវលើជនរងគ្រោះ) និងមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមូលដ្ឋាន។

នៅពេលជនរងគ្រោះត្រូវបានផ្ទេរពីមណ្ឌល បុគ្គលទាំងឡាយខាងលើ ត្រូវចុះហត្ថលេខាលើលិខិតផ្ទេរ។

លិខិតទទួល និងផ្ទេរជនរងគ្រោះ ត្រូវមានពត៌មានដូចខាងក្រោម:

១) ឈ្មោះ និង អាយុជនរងគ្រោះ

២) ឈ្មោះឪពុក-ម្ដាយ ឬអ្នកតំណាងជនរងគ្រោះ

៣) ឈ្មោះទីភ្នាក់ងារគាំទ្រជនរងគ្រោះ និងឈ្មោះប្រធានមណ្ឌល

៤) ឈ្មោះមន្ត្រីទទួលបន្ទុក សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាថ្នាក់មូលដ្ឋាន

៥) ស្ថានភាព និង កាលៈទេសៈ ជនរងគ្រោះពេលសង្គ្រោះ និងពេលនាំទៅកាន់មណ្ឌល

៦) លក្ខខ័ណ្ឌសុខភាពជនរងគ្រោះ

៧) រយៈពេលព្រៀងទុកសំរាប់ជនរងគ្រោះដែលនឹងត្រូវរស់នៅក្នុងមណ្ឌល

៨) ការអប់រំ ឬការបណ្ដុះបណ្ដាលដែលមានសំរាប់ជនរងគ្រោះ

៩) ព័តមានក្នុងការទំនាក់ទំនងសាច់ញាតិ ឬមិត្តភ័ក្រជនរងគ្រោះ ។

**ប្រការ ៦៤.-**

ប្រធានមណ្ឌលត្រូវផ្ដល់បញ្ជីដែលរួមមាន ឈ្មោះ ភេទ រូបថត ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត ពត៌មានសុខភាព និងរយៈពេលស្នាក់នៅក្នុងមណ្ឌលរបស់ជនរងគ្រោះ ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ បញ្ជីនេះត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវរក្សាការសំងាត់នៃពត៌មាននេះ ។

ក្រោយពេលជនរងគ្រោះបានចាកចេញពីមណ្ឌលរយៈពេលបីឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមណ្ឌល អាចសំរេចចិត្តក្នុងការប្រគល់ឯកសារនោះទៅឱ្យជនរងគ្រោះ ឬឯកសារនោះ អាចត្រូវបំផ្លាញចោល ប្រសិនបើជនរងគ្រោះមិនចង់បានទេ។ នៅក្នុងចន្លោះពេលនេះ ទោះបីជាយ៉ាងណាក៏ដោយ ជនរងគ្រោះ អាចទាមទារយកឯកសាររបស់គេ ពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងមណ្ឌល បានគ្រប់ពេលវេលា។

**ប្រការ ៦៥.-**

ក្នុងករណីជនណាម្នាក់ដែលបានអះអាងថា ខ្លួនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ហើយសុំស្នាក់នៅក្នុងមណ្ឌលដោយខ្លួនឯង ប្រធានមណ្ឌល ត្រូវផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរ ទៅឱ្យសមត្ថកិច្ចនគរបាលមូលដ្ឋានជាបន្ទាន់ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**ប្រការ ៦៦.-**

ជនរងគ្រោះ មានសិទ្ធិស្នើសុំចាកចេញរហូត ពីមណ្ឌលទៅរស់នៅក្នុងគ្រួសារ ឬសហគមន៍វិញ។ ក្នុងករណីជនរងគ្រោះជានីតិជន មានបំណងចេញពីមណ្ឌលរហូតនោះ ប្រធានមណ្ឌលពុំមានសិទ្ធហាមឃាត់ជននោះឡើយ។ ករណីនេះ ប្រធានមណ្ឌលត្រូវរាយការណ៍ជូនទៅ មន្ទីរ ឬការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយបន្ទាប់មក មន្ទីរ ឬការិយាល័យត្រូវជូនព័តមាន ដល់នគរបាលទទួលរឿងក្តី ហើយមណ្ឌល ត្រូវផ្តល់ពត៌មានទៅឱ្យនគរបាលការពារសុវត្ថិភាព។

ប៉ុន្តែ បើជនរងគ្រោះជាអនីតិជនមានបំណងចាកចេញពីមណ្ឌលរហូតនោះ មណ្ឌលអាចនឹងប្រឹក្សាយោបល់ និងលើកទឹកចិត្តអោយកុមារបន្តរស់នៅក្នុងមណ្ឌល ប៉ុន្តែមិនបង្ខំអោយកុមារនៅក្នុងមណ្ឌល ដោយគេមិនចង់នោះទេ។ នៅពេលកុមារម្នាក់បានសំរេចចិត្តចាកចេញពីមណ្ឌល មណ្ឌលត្រូវធានាថា មានសាច់ញាតិ ឬអាណាព្យាបាល ឬអ្នកទទួលខុសត្រូវ ឬទីភ្នាក់ងារដទៃទៀត នឹងថែទាំកុមារនោះ និងទទួលព័តមានលំអិតដើម្បីធ្វើការទំនាក់ទំនងជាមួយជនរងគ្រោះនៅពេលក្រោយ ។

ប្រសិនបើអនីតិជន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មណ្ឌលរដ្ឋ នោះប្រធានមណ្ឌល ត្រូវសុំការសំរេចពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ប៉ុន្តែចំពោះប្រធានមណ្ឌល របស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវជូនពត៌មានទៅឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងនគរបាលជំនាញ។

ក្នុងករណី ជនរងគ្រោះណាម្នាក់ចង់ចាកចេញពីមណ្ឌលរហូត ហើយរឿងក្តីរបស់ជនរងគ្រោះនោះ កំពុងស្ថិតនៅក្រោមការស៊ើបអង្កេត ឬចោទប្រកាន់ ប្រធានមណ្ឌលត្រូវជូនពត៌មានទៅឱ្យនគរបាល ឬព្រះរាជអាជ្ញាឱ្យបានមុន និងឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

**ប្រការ ៦៧.-**

ក្នុងករណីមានជនណា មានបំណងយកជនរងគ្រោះចេញពីមណ្ឌល ហើយមណ្ឌលមានហេតុផលសមស្រប ថា ជននោះមានបំណងជួញដូរជនរងគ្រោះសារជាថ្មី នោះមណ្ឌលមានសិទ្ធិរក្សាទុកជនរងគ្រោះ ដោយប្រើសិទ្ធិគ្រប់គ្រងជនរងគ្រោះ។ មណ្ឌលត្រូវជូនដំណឹងទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អំពីស្ថានភាពនេះ។

**ប្រការ ៦៨.-**

ក្នុងករណីជនណាចង់យកជនរងគ្រោះពីមណ្ឌល ហើយមណ្ឌលមិនយល់ព្រម ជននោះអាចប្តឹងទៅ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីជួយដោះស្រាយ។ ប្រសិនបើមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនមានលទ្ធភាពដោះស្រាយ ឬភាគីណាមួយមិនសុខចិត្តទៅនឹងសេចក្តីសំរេចរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ភាគីនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការ។ នៅក្នុងរយះពេលនៃបណ្តឹងទាំងនេះ ជនរងគ្រោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មណ្ឌល។

**ប្រការ ៦៩.-**

ប្រសិនបើបុគ្គលណាបានយកជនរងគ្រោះចេញពីមណ្ឌល ដោយមធ្យោបាយណាមួយក៏ដោយ ដោយមិនមានការយល់ព្រមពីមណ្ឌល មណ្ឌលត្រូវរាយការណ៍ទៅនគរបាលមូលដ្ឋាន និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីចាត់វិធានការបន្ត។

**ប្រការ ៧០.-**

ជនរងគ្រោះ ឬអ្នកពាក់ព័ន្ធ អាចប្តឹងទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំពោះភាពមិនប្រក្រតីនៃការគ្រប់គ្រង និងបញ្ហាផ្សេងៗទៀតរបស់មណ្ឌល។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើការស៊ើបអង្កេតអោយបានឆាប់រហ័ស និង ឬត់ចត់ លើបណ្តឹងនោះ។

**ប្រការ ៧១.-**

ក្នុងករណី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រកឃើញថាមណ្ឌលមានកំហុសឆ្គង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ ត្រូវធ្វើការណែនាំទៅមណ្ឌលនោះ។

ក្នុងករណីមណ្ឌលប្រព្រឹត្តកំហុសឆ្គងជាលើកទីពីរ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសិទ្ធិដកហូតអំណាចគ្រប់គ្រងលើជនរងគ្រោះនោះ ពីមណ្ឌលនោះទាំងស្រុង។

### ប្រការ ៧២._

សិទ្ធិគ្រប់គ្រងលើជនរងគ្រោះរបស់មណ្ឌលនឹងត្រូវបាត់បង់ នៅពេលជនរងគ្រោះ បានចាកចេញពី មណ្ឌល តាមការសម្រេចចិត្តរបស់ជនរងគ្រោះ ឬជនរងគ្រោះរត់ចេញពីមណ្ឌល ឬឪពុក-ម្តាយទទួលយកវិញ ឬបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមការធ្វើសមាហរណកម្ម។ ប៉ុន្តែមណ្ឌលនៅតែមានសិទ្ធិគ្រប់គ្រងលើជនរងគ្រោះ ក្នុងករណីជនរងគ្រោះចាកចេញពីមណ្ឌល ដូចមាន ចែងនៅក្នុងប្រការ ៦៩។

មណ្ឌលនឹងបាត់បង់ សិទ្ធិគ្រប់គ្រង ក្នុងករណីជនរងគ្រោះស្លាប់។ ក្នុងករណីនេះ មណ្ឌលត្រូវជូនដំណឹងទៅ នគរបាលមូលដ្ឋាន និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូក១១_ទីភ្នាក់ងារទំនាក់ទំនងដំបូង

### ប្រការ ៧៣._

ទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវចាត់វិធានការ ដែលអាចធ្វើទៅបាន ដើម្បីធានាថាជនរងគ្រោះ ដែលបានធ្វើការទំនាក់ទំនងជាមួយខ្លួន បានដឹងពីប្រភេទផ្សេងៗនៃសេវាដែលមាន និងដឹងពីរបៀបទទួលបាន សេវាទាំងនោះ ហើយទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវជួយជនរងគ្រោះទៅកាន់មណ្ឌលណាមួយ ប្រសិនបើ ជនរងគ្រោះ ចង់ទៅកាន់មណ្ឌលនោះ។

ទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវជូនដំណឹងភ្លាម ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រសិនបើ ទីភ្នាក់ងារនេះ ផ្តល់ជំរកស្នាក់នៅបណ្តោះអាសន្នដល់ជនរងគ្រោះ មុននឹងបញ្ជូនជនរងគ្រោះទៅកាន់ មណ្ឌលណាមួយនោះ។ នៅពេលបញ្ជូនជនរងគ្រោះទៅមណ្ឌលណាមួយ ទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវជូនដំណឹង ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងនគរបាលមូលដ្ឋានផងដែរ។

### ប្រការ ៧៤._

ទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវរក្សាទុកជនរងគ្រោះ តែក្នុងកាលៈទេសៈចាំបាច់បំផុត ដូចជាថ្ងៃឈប់សម្រាក ផ្លូវមិនល្អ ពេលយប់ និងមណ្ឌលស្ថិតនៅឆ្ងាយ។

ទីភ្នាក់ងារទំនាក់ទំនងដំបូង ត្រូវរក្សាទុកជនរងគ្រោះក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន។

### ប្រការ ៧៥._

ជនរងគ្រោះភាគច្រើន ទទួលរងផលប៉ះពាល់ផ្នែករាងកាយ និងផ្លូវចិត្ត។ ដូចនេះ ទីភ្នាក់ងារទំនាក់ទំនង ដំបូង ត្រូវអនុវត្តតាមបទដ្ឋានអប្បបរមា មុនពេលបញ្ជូនជនរងគ្រោះទៅកាន់មណ្ឌល។

ទីភ្នាក់ងារទំនាក់ទំនងដំបូងគួរមាន អ្នកប្រឹក្សាយោបល់ ឬបុគ្គលិកសង្គម ទឹកស្អាត របបអាហារ កន្លែងដេកសមរម្យ និងការថែរក្សាសុខភាព។

## ជំពូក១២ ការធ្វើសមាហរណកម្ម

**ប្រការ ៧៦.-**

នៅក្នុងការធ្វើសមាហរណកម្មជនរងគ្រោះ មណ្ឌលត្រូវបំពេញបែបបទដូចមានចែងក្នុងប្រការ ៦៣ និង បញ្ជាក់ពីសកម្មភាពជនរងគ្រោះ នៅក្នុងរយៈពេលស្នាក់នៅក្នុងមណ្ឌល។ ក្នុងករណីជនរងគ្រោះជាអនីតិជន ឯកសារនោះ ត្រូវបញ្ជាក់ពត៌មានបុគ្គលដែលនឹងថែរក្សាជនរងគ្រោះបន្ត ទីកន្លែងដែលជនរងគ្រោះទៅ (ភូមិ-ឃុំ) និងនីតិវិធីតាមដាន វាយតំលៃជនរងគ្រោះ។ មណ្ឌលត្រូវរៀបចំអោយមាន ការចូលរួមក្នុងដំណើរការ សមាសហរណកម្ម ពីឪពុក-ម្តាយ ឬ សាច់ញាតិ ក្នុងស្ថានភាពមួយតាមដែលអាចធ្វើទៅបាន។

**ប្រការ ៧៧.-**

ចំពោះការធ្វើសមាហរណកម្មជនរងគ្រោះដែលមានជំនាញជាក់លាក់ មណ្ឌល (បើអាចធ្វើទៅបាន) គួររៀបចំ និងសំរបសំរួល អោយជនរងគ្រោះមានឱកាសទទួលបានការឧបត្ថម្ភ ឬប្រាក់កម្ចី ដើម្បីប្រកបមុខរបរ ទៅតាមជំនាញវិជ្ជាជីវៈដែលបានទទួល។ ប្រាក់កម្ចីទាំងនោះមិនត្រូវមានការប្រាក់ទេ ហើយត្រូវអោយសងវិញ ជាដំណាក់កាលបន្តិចម្តងៗ។

**ប្រការ ៧៨.-**

ក្រោយពេលធ្វើសមាហរណកម្មជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយ ទីភ្នាក់ងារគាំទ្រជនរងគ្រោះ ឬមណ្ឌល និងក្រសួងកិច្ចការនារី ក្នុងការពិនិត្យតាមដាន និងវាយតំលៃជនរងគ្រោះ ដើម្បីទប់ស្កាត់ការជួញដូរមនុស្សជាថ្មីឡើងវិញ។ ប៉ុន្តែករណីនេះ មិនគ្របដណ្តប់លើ ជនរងគ្រោះជាជនបរទេស ដែលធ្វើមាតុភូមិនិវត្តនោះឡើយ។

## ជំពូក១៣ កិច្ចសហប្រតិបត្តិការរបស់ភាគីនានា

**ប្រការ ៧៩.-**

រាល់រឿងក្តីពាក់ព័ន្ធអំពើជួញដូរមនុស្ស ភាគីទាំងអស់ត្រូវសហការដោះស្រាយអោយបានឆាប់រហ័ស។

**ប្រការ ៨០.-**

ភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

ប្រការ ៨១.-

កិច្ចព្រមព្រៀងនេះ នឹងអាចកែប្រែបាន លុះត្រាតែមានការឯកភាពពីភាគីហត្ថលេខី តាមការស្នើសុំរបស់ភាគីណាមួយ។

ប្រការ ៨២.-

ស្ថាប័នរាជរដ្ឋាភិបាល ឬ ទីភ្នាក់ងារគាំទ្រជនរងគ្រោះ ណាដែលមិនមែនជាហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ អាចបន្តសុំចុះហត្ថលេខា គិតចាប់ពីថ្ងៃចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះតទៅ ហើយបញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះហត្ថលេខា ត្រូវបានរក្សាទុកនៅ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

ហត្ថលេខារបស់ភាគីនៃកិច្ចព្រមព្រៀងនេះ

<u>ភាគីស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ</u>

| ក្រសួងយុត្តិធម៌ | ក្រសួងមហាផ្ទៃ |
| --- | --- |
| ឯកឧត្តម អ៊ី ចន<br>រដ្ឋលេខាធិការ | ឯកឧត្តម នាយឧត្តមសេនីយ៍<br>ខាន់ សាវឿន<br>រដ្ឋលេខាធិការ |

| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ក្រសួងកិច្ចការនារី | ក្រសួងសុខាភិបាល |
| --- | --- | --- |
| ឯកឧត្តម សយ ស៊ីផុន<br>រដ្ឋលេខាធិការ | លោកជំទាវ យូ អយ<br>រដ្ឋលេខាធិការ | លោកជំទាវ អ៊ុក ម៉ុណ្ណា<br>រដ្ឋលេខាធិការ |

<u>ភាគីពាក់ព័ន្ធការគាំទ្រជនរងគ្រោះ</u>

| អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | អង្គការវឌ្ឍនភាព |
|---|---|
| អ្នកស្រី អ៊ុង ចន្ទថុល<br>នាយិកាប្រតិបត្តិ | លោក នុយ ថូរ៉ា<br>នាយក |

| មជ្ឈមណ្ឌលថែទាំសុខភាពកុមារ | សមាគមកុមាររីករាយ | អង្គការការពារយុត្តិធម៌កុមារ |
|---|---|---|
| កញ្ញា លី សុន្ទរី<br>នាយិកាប្រតិបត្តិ | អ្នកស្រី ព្រហ្ម គឹមសេង<br>នាយិកាប្រតិបត្តិ | អ្នកស្រី ស៊ឹម ស៊ុយាង<br>នាយិកា |

| | |
|---|---|
| អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី<br><br>អ្នកស្រី ឈី ទិដ្ឋុនា<br>នាយិកា | អង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា<br><br>ហ៊ុន ដាណ្ណា<br>អ្នកសំរបសំរួលកម្មវិធី |
| អង្គការកុមារមើលឃើញការអប់រំ និងការចូលរួម<br><br>លោក សេន ទុំស្វាហ្សា<br>ប្រធានស្ដីទី | សមាគមកុមារកម្ពុជា ប្រឆាំងទុរភិក្ស និង ជំងឺ<br><br>លោក តោគ ម៉ុនរឿន<br>នាយកប្រតិបត្តិ |
| សមាគមគ្រូគ្រប់កុមារកម្ពុជាថ្មី<br><br>លោក នួន ឆន<br>ប្រធាន | អង្គការពន្លឺកុមារកម្ពុជា<br><br>លោក សួន ម៉ារ៉ៃឡុចុន<br>នាយកប្រតិបត្តិ |

| | |
|---|---|
| អង្គការច្បាប់តាជីង<br><br>លោក ឆម វុទ្ធី<br>ប្រធានស្ដីទី | មណ្ឌលសំចតដោយបើក<br><br>អ្នកស្រី ឈា ម៉ានិត<br>ប្រធាន |
| មណ្ឌលបំរើគ្រួសារអនាថា ( ផ្ទះទឹកថ្លង)<br><br>អ្នកស្រី គ្រាត់ សុខានី<br>នាយិកាប្រតិបត្តិ | អង្គការតំណក់ទឹកកម្ពុជា<br><br>វេជ្ជបណ្ឌិត សំ សុវណ្ណារិទ្ធិ<br>នាយកប្រតិបត្តិ |
| សមាគមកុមារ និងក្តីស្រឡាញ់<br><br>អ្នកស្រី ប៊ុត សាម៉ន<br>នាយិកាប្រតិបត្តិ | មជ្ឈមណ្ឌលកម្ពុជា ដើម្បីការពារសិទ្ធិកុមារ<br><br>លោក យឹម ប៉ូ<br>នាយកប្រតិបត្តិ |

<table>
<tr>
<td colspan="2">Association Internationale pour le Développement, le Tourisme et la Santé (AIDéTouS)<br><br>Ms. Marina Protopopoff<br>Country Representative</td>
<td>អង្គការកម្ពុជានៃក្តីសង្ឃឹម<br><br>លោក សួន កុសល្យ<br>នាយកស្តីទី</td>
</tr>
<tr>
<td colspan="2">គណៈកម្មាធិការបំបាត់ទេសចរ ការរំលោភ<br>និងការជួញដូរមនុស្សនៅកម្ពុជា<br><br>លោក ជីន ច័ន្ទទាសនា<br>នាយកប្រតិបត្តិ</td>
<td>អង្គការកុមារនៃក្តីសង្ឃឹម<br><br>សុខ សុគ្នាវី<br>នាយិកា</td>
</tr>
<tr>
<td>ជំនួយ ផ្នែកច្បាប់នៃកម្ពុជា<br><br>ពីខ យក់ ហៀប<br>នាយិកា</td>
<td>អង្គការអនាគតកុមារ<br><br>ខែម សុខុន<br>នាយក</td>
<td>អង្គការកុមារឥតព្រំដែន<br><br>គង់ សុភា<br>ប្រធានកម្មវិធី</td>
</tr>
</table>